ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

សុន្ទរកថា
ឯកឧត្តម គួយ ប៊ុនរឿន អនុប្រធាន គ.ជ.ប
ក្នុងពិធីបិទកិច្ចប្រជុំពិគ្រោះយោបល់
លើសេចក្តីព្រាងបទបញ្ជា និងនីតិវិធីសម្រាប់ការធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោត និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១៧

(រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១៧)

សូមគោរព

- ឯកឧត្តម លោកជំទាវ សមាជិក សមាជិកា គ.ជ.ប
- លោក តាកេហារ៉ូ គូជីម៉ា (Takeharu Kojima) អ្នកតំណាងជាន់ខ្ពស់ អង្គការ JICA
- ឯកឧត្តម លោកជំទាវ លោក លោកស្រីតំណាងស្ថាប័នរដ្ឋ គណបក្សនយោបាយ អង្គការមិនមែនរដ្ឋាភិបាល និងអ្នកសារព័ត៌មានជាតិ អន្តរជាតិ
- ឯកឧត្តម លោក លោកស្រីជាថ្នាក់ដឹកនាំ និងមន្ត្រីនៃអគ្គលេខាធិការដ្ឋាន គ.ជ.ប
- លោក លោកស្រីតំណាងអង្គការ JICA អ្នកជំនាញការជប៉ុន អ្នកជំនាញការសហភាពអឺរ៉ុប និងអ្នកជំនាញការអង្គការ IFES

ថ្ងៃនេះ ខ្ញុំមានសេចក្តីសោមនស្សរីករាយ ដែលបានមកចូលរួមជាមួយឯកឧត្តម លោកជំទាវ លោក លោកស្រីក្នុងពិធីបិទកិច្ចប្រជុំពិគ្រោះយោបល់លើសេចក្តីព្រាងបទបញ្ជា និងនីតិវិធីសម្រាប់ការធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោត និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១៧ នាពេលនេះ។

កិច្ចពិគ្រោះយោបល់ដ៏មានសារៈសំខាន់នេះ ធ្វើឡើងក្នុងគោលបំណងស្វែងរកការផ្តល់យោបល់ និងគំនិតល្អៗពីភាគីពាក់ព័ន្ធទាំងអស់ សម្រាប់ធ្វើការកែលម្អ និងបន្ថែមនូវខ្លឹមសារមួយចំនួនទៀត ដើម្បីឱ្យសេចក្តីព្រាងបទបញ្ជា និងនីតិវិធីនេះ ឱ្យក្លាយទៅជាលិខិតបទដ្ឋានគតិយុត្តដែលមានភាពត្រឹមត្រូវ ច្បាស់លាស់ ស្របតាមច្បាប់ជាធរមាន សម្រាប់ធានាដល់ការធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោត និងការចុះឈ្មោះបោះឆ្នោត ដើម្បីបម្រើឱ្យការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦ នៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៨ នាពេលខាងមុខ ប្រព្រឹត្តទៅមានលក្ខណៈសេរី ត្រឹមត្រូវ និងយុត្តិធម៌។

ឯកឧត្តម លោកជំទាវ លោក លោកស្រីជាទីគោរព!

នេះជាលើកទីបីហើយដែល គ.ជ.ប បានសហការជាមួយនឹងអង្គការ JICA និងសហភាពអ៊ឺរ៉ុប ក្នុងការរៀបចំកិច្ចប្រជុំពិគ្រោះយោបល់នេះឡើង ដែលការរៀបចំលើកទីមួយ កាលពីថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៦ ក្នុងដំណាក់កាលត្រៀមលក្ខណៈធ្វើការចុះឈ្មោះបោះឆ្នោត ដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មី ឆ្នាំ២០១៦ និងលើកទីពីរ កាលពីថ្ងៃទី០៥ ខែមករា ឆ្នាំ២០១៧ ក្នុងការត្រៀមលក្ខណៈធ្វើការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ ឆ្នាំ២០១៧។ ឆ្លងតាមរយៈការចូលរួមផ្តល់ជាយោបល់ និងអនុសាសន៍របស់ភាគីពាក់ព័ន្ធកន្លងមកលើបទបញ្ជា និងនីតិវិធីសម្រាប់ការចុះឈ្មោះបោះឆ្នោត ដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មី ឆ្នាំ២០១៦ និងបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ ឆ្នាំ២០១៧ បានធ្វើឱ្យដំណើរការនៃការចុះឈ្មោះបោះឆ្នោត និងការបោះឆ្នោតដែលទើបនឹងបញ្ចប់កន្លងទៅថ្មីៗនេះ ទទួលបានលទ្ធផលគួរជាមោទនៈ ដោយមានប្រជាពលរដ្ឋខ្មែរចំនួន **៧,៨៦៥,០៣៣ នាក់** បានមកចុះឈ្មោះបោះឆ្នោតស្មើនឹង **៨១,៣៨ ភាគរយ** នៃប្រជាពលរដ្ឋដែលមានសិទ្ធិចុះឈ្មោះបោះឆ្នោត ហើយប្រជាពលរដ្ឋខ្មែរចំនួន **៧,១០៧,៣៩៥** នាក់ ស្មើនឹង **៩០,៣៧%** នៃចំនួនប្រជាពលរដ្ឋខ្មែរដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោត បានចេញទៅបោះឆ្នោត។

សមិទ្ធផលដែល គ.ជ.ប ទទួលបានជោគជ័យខាងលើនេះ កើតចេញពីការខិតខំប្រឹងប្រែងរបស់មន្ត្រីបោះឆ្នោតគ្រប់ជាន់ថ្នាក់ និងក្រុមចុះឈ្មោះបោះឆ្នោត ប្រជាពលរដ្ឋដែលបានចូលរួមបោះឆ្នោត អាជ្ញាធរគ្រប់លំដាប់ថ្នាក់ គណៈបញ្ជាការឯកភាពសន្តិសុខបោះឆ្នោតគ្រប់ជាន់ថ្នាក់ គណបក្សនយោបាយ អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ ព្រមទាំងភាគីពាក់ព័ន្ធដទៃទៀត ហើយក៏មានការគាំទ្រផងដែរលើផ្នែកថវិកា ឧបករណ៍សម្ភារ បច្ចេកទេសពីរាជរដ្ឋាភិបាលកម្ពុជា និងសហគមន៍អន្តរជាតិ។

បច្ចុប្បន្ននេះ ដោយអនុវត្តតាមផែនការមេ និងប្រតិទិនស្តីពីការធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោត និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១៧ គ.ជ.ប បានរៀបចំសេចក្តីព្រាងបទបញ្ជា និងនីតិវិធីសម្រាប់ការធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោត និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១៧ ហើយបានផ្ញើទៅកាន់បណ្តាភាគីពាក់ព័ន្ធចំនួន ៣៧ ស្ថាប័នរួចបានទទួលនូវអនុសាសន៍ជាលាយលក្ខណ៍អក្សរមកវិញចំនួន ១៤ ស្ថាប័ន ដែលបណ្តាអនុសាសន៍ទាំងអស់នោះត្រូវបានអគ្គលេខាធិការដ្ឋាន គ.ជ.ប ពិនិត្យ និងពិភាក្សាជាបឋម ហើយបានដាក់ជូនកិច្ចប្រជុំពិគ្រោះយោបល់នាថ្ងៃនេះ ដើម្បីជួយផ្តល់យោបល់ជាលើកចុងក្រោយនាថ្ងៃនេះ មុននឹង គ.ជ.ប សម្រេច អនុម័តជាផ្លូវការ។

ឯកឧត្តម លោកជំទាវ លោក លោកស្រី!

ក្នុងនាម គ.ជ.ប ខ្ញុំសូមអនុញ្ញាតចូលរួមជាយោបល់ឆ្លើយតបទៅនឹងរាល់អនុសាសន៍របស់ភាគីពាក់ព័ន្ធទាំងអស់ តាមជំពូកនីមួយៗ ដែលបានផ្តល់ជូន គ.ជ.ប កាលពីចុងខែកក្កដា ឆ្នាំ២០១៧ កន្លងទៅ និងអនុសាសន៍បន្ថែមនៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់ ដែលឯកឧត្តម លោកជំទាវ លោក លោកស្រីបានពិភាក្សាយ៉ាងផុលផុសក្នុងរយៈពេលពេញមួយថ្ងៃនេះ ដូចខាងក្រោម៖

ជំពូកទី១ បទប្បញ្ញត្តិទូទៅ

ក្នុងជំពូកនេះ គ.ជ.ប បានធ្វើការកែសម្រួលខ្លឹមសារមួយចំនួន តាមការស្នើសុំរបស់ភាគីពាក់ព័ន្ធមួយចំនួន។

ជំពូកទី២ ការគ្រប់គ្រងការធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោត និងការចុះឈ្មោះបោះឆ្នោត

- ចំពោះយោបល់របស់ភាគីពាក់ព័ន្ធក្នុងជំពូកនេះ គ.ជ.ប កត់សម្គាល់ឃើញថា មានការផ្តល់យោបល់កែសម្រួលលើខ្លឹមសារមួយចំនួនឱ្យស្របតាមស្មារតីនៃច្បាប់បោះឆ្នោត និងលិខិតបទដ្ឋានពាក់ព័ន្ធ ក្នុងនោះមានចំណុចមួយចំនួន គ.ជ.ប បានទទួលយក ដើម្បីធ្វើការកែសម្រួលក្នុងបទបញ្ជា និងនីតិវិធីនេះ ហើយចំណុចខ្លះ ដូចជា យន្តការសន្តិសុខ សុវត្ថិភាព ក្នុងការធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោត និងចុះឈ្មោះបោះឆ្នោត គ.ជ.ប បានកែសម្រួលទៅជា ការអនុវត្តតាមផែនការអន្តរស្ថាប័នក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ និង គ.ជ.ប អំពីការងារសន្តិសុខនេះ។
- ដោយឡែកទាក់ទងនឹងការកិច្ចរបស់លេខាធិការដ្ឋានរាជធានី ខេត្ត រៀបចំការបោះឆ្នោត ដែលទទួលបញ្ជីលុបឈ្មោះអ្នកបោះឆ្នោតពីស្មៀនឃុំ សង្កាត់ រៀងរាល់ពីរខែម្តងនេះ មានយោបល់ស្នើសុំឱ្យបន្ថែមការប្តូរការិយាល័យបោះឆ្នោត។ ចំពោះចំណុចនេះ គ.ជ.ប រក្សាខ្លឹមសារដដែល ពីព្រោះ គ.ជ.ប អនុវត្តតាមច្បាប់បោះឆ្នោត ហើយអ្នកបោះឆ្នោតដែលមានបំណងប្តូរការិយាល័យបោះឆ្នោត អាចស្នើសុំប្តូរក្នុងអំឡុងពេលអនុវត្តការងារធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោត និងចុះឈ្មោះបោះឆ្នោត ៧០ ថ្ងៃ តាមឃុំ សង្កាត់។

ជំពូកទី៣ ការបណ្តុះបណ្តាលអប់រំអ្នកបោះឆ្នោត និងការងារព័ត៌មានសាធារណៈ

ក្នុងជំពូកទី៣ នេះ មានស្ថាប័នមួយចំនួនបានជូនយោបល់លើបញ្ហាការងារបណ្តុះបណ្តាល ការផ្សព្វផ្សាយអប់រំអ្នកបោះឆ្នោត និងការស្នើសុំកិច្ចសហការគាំទ្រពីភាគីពាក់ព័ន្ធលើការផ្សព្វផ្សាយការអប់រំអ្នកបោះឆ្នោត។ យោបល់ទាំងនេះ គ.ជ.ប បានទទួលយកដើម្បីដាក់បញ្ចូលក្នុងបទបញ្ជា និងនីតិវិធីនេះ ប៉ុន្តែ គ.ជ.ប សូមបញ្ជាក់ជូនផងដែរថា ការចូលរួមរបស់ភាគីពាក់ព័ន្ធអំពីការអប់រំផ្សព្វផ្សាយព័ត៌មានទាក់ទងនឹងការចុះឈ្មោះបោះឆ្នោតជូនប្រជាពលរដ្ឋនៅតាមមូលដ្ឋាន ត្រូវតែស្នើសុំពីអាជ្ញាធរមានសមត្ថកិច្ចជាមុន ហើយគ្រប់សកម្មភាពត្រូវអនុវត្តក្នុងក្របខណ្ឌច្បាប់ពាក់ព័ន្ធជាធរមាន។

- យន្តការថ្នាក់ជាតិ សម្រាប់ការផ្លាស់ប្តូរព័ត៌មាន ការអន្តរាគមន៍ និងការសម្របសម្រួលបញ្ហានានាក្នុងដំណើរការបោះឆ្នោត។ ជាទូទៅយន្តការនេះ គ.ជ.ប បានអនុវត្តរួចរាល់ហើយ តាមរយៈការរៀបចំឱ្យមានកិច្ចប្រជុំជាមួយភាគីពាក់ព័ន្ធជាតិ និងអន្តរជាតិជាទៀងទាត់ ទាំងថ្នាក់ គ.ជ.ប ទាំងថ្នាក់រាជធានី ខេត្ត ទៅតាមដំណាក់កាលនីមួយៗ ហើយចំពោះចំណុចនេះ គ.ជ.ប នឹងពិនិត្យពិចារណារកនីតិវិធី និងយន្តការបន្ថែមទៀត ដើម្បីដោះស្រាយបញ្ហារួមទាំងអស់គ្នា។

ជំពូកទី៤ ការិយាល័យចុះឈ្មោះបោះឆ្នោត និងការិយាល័យបោះឆ្នោត

យោបល់របស់ភាគីពាក់ព័ន្ធភាគច្រើនដែលបានផ្តល់ក្នុងជំពូកនេះ មានស្មើរគ្រប់ចំណុច គឺស្នើសុំឱ្យ គ.ជ.ប ពង្រឹងការអនុវត្តការងារលើការយកចិត្តទុកដាក់ចំពោះជនពិការភាពដោយកំណត់ស្ថានភាពពិការភាពក្នុងបញ្ជីបោះឆ្នោត ការកំណត់ទីតាំងការិយាល័យបោះឆ្នោត ការិយាល័យចុះឈ្មោះបោះឆ្នោត ជាដើម។ ទាក់ទងនឹងយន្តការពង្រឹងការអនុវត្ត គ.ជ.ប សូមទទួលយក ហើយចំណុចមួយចំនួន គ.ជ.ប សូមធ្វើការបញ្ជាក់ដូចខាងក្រោម៖

- មានការលើកឡើងថា គួរដាក់សញ្ញាកំណត់អំពីបរិវេណខាងក្នុង និងបរិវេណខាងក្រៅ។ ចំណុចនេះ ជាគោលការណ៍បរិវេណខាងក្នុង ១៥ ម៉ែត្រ និងបរិវេណខាងក្រៅ ១០០ ម៉ែត្រ ប៉ុន្តែបរិវេណនេះ អាចមានការប្រែប្រួលទៅតាមទម្រង់ ឬស្ថានភាពជាក់ស្តែងនៃទីកន្លែងដែលត្រូវរៀបចំការិយាល័យជាក់ស្តែង។
- អំពីការបង្កើតមណ្ឌលចុះឈ្មោះបោះឆ្នោតតាមទីប្រមូលផ្តុំ។ ចំណុចនេះជាគោលការណ៍ គ.ជ.ប មិនអាចអនុវត្តបានទេ ផ្អែកតាមទិដ្ឋភាពច្បាប់បោះឆ្នោតបានកំណត់ច្បាស់អំពីលក្ខខណ្ឌចុះឈ្មោះបោះឆ្នោត សមាសភាពក្រុមចុះឈ្មោះបោះឆ្នោត ដែលត្រូវអនុវត្តក្នុងក្របខណ្ឌឃុំ សង្កាត់រៀងៗខ្លួន។ ប៉ុន្តែចំណុចនេះ គ.ជ.ប លើកទឹកចិត្តឱ្យភាគីពាក់ព័ន្ធចូលរួមផ្សព្វផ្សាយអប់រំអ្នកបោះឆ្នោតឱ្យបានទូលំទូលាយឱ្យទៅចុះឈ្មោះបោះឆ្នោតតាមប្រតិទិនបែងចែករបស់ក្រុមចុះឈ្មោះបោះឆ្នោត។

- ចំពោះការរៀបចំការចុះឈ្មោះបោះឆ្នោតនៅតាមបន្ទាត់ព្រំដែន ឬក្រៅប្រទេស។ ចំពោះបញ្ហានេះ ឯកឧត្តមប្រធាន គ.ជ.ប បានលើកឡើងបញ្ជាក់អំពីស្មារតីរបស់ គ.ជ.ប រួចហើយ។ ផ្អែកតាមស្មារតីរដ្ឋធម្មនុញ្ញ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃ គ.ជ.ប និងច្បាប់បោះឆ្នោត មិនអនុញ្ញាតឱ្យ គ.ជ.ប អនុវត្តបានឡើយ។
- ការការពារសន្តិសុខក្នុងការិយាល័យបោះឆ្នោត។ ចំណុចនេះ គ.ជ.ប ក៏បានពិចារណា និងមានវិធានការរួចហើយ គឺយើងអនុវត្តក្នុងក្របខណ្ឌបរិវេណការិយាល័យចុះឈ្មោះបោះឆ្នោតតែប៉ុណ្ណោះ គឺមិនប៉ះពាល់ដល់ដំណើរការងាររដ្ឋបាលរបស់ឃុំ សង្កាត់ឡើយ។
- ចំពោះអនុសាសន៍មួយចំនួនទៀត គ.ជ.ប សូមមិនធ្វើការបញ្ជាក់នាពេលនេះទេ ដោយហេតុថា ចំណុចខ្លះ គ.ជ.ប បានទទួលយក និងចំណុចខ្លះក៏មិនទទួលយកចំណុចមួយចំនួន គ.ជ.ប នឹងបន្តពិភាក្សាក្នុងអង្គប្រជុំ គ.ជ.ប។

ជំពូកទី៥ ភ្នាក់ងារគណបក្សនយោបាយ អ្នកសង្កេតការណ៍ និងអ្នកសារព័ត៌មាន

មានយោបល់មួយចំនួនដែលបានលើកឡើងក្នុងជំពូកនេះ ត្រូវបាន គ.ជ.ប ទទួលយកបញ្ចូលក្នុងបទបញ្ជា និងនីតិវិធីនេះ ប៉ុន្តែមានចំណុចខ្លះ គ.ជ.ប សូមធ្វើការបំភ្លឺ ដូចខាងក្រោម៖

- អំពីភ្នាក់ងារគណបក្សនយោបាយ។ អនុវត្តតាមច្បាប់បោះឆ្នោតតម្រូវឱ្យគណបក្សនយោបាយដែលបានចុះបញ្ជីត្រឹមត្រូវនៅក្រសួងមហាផ្ទៃចាត់តាំងតំណាង ២ រូប ក្នុងនោះពេញសិទ្ធិ ១ រូប និងបម្រុង ១ រូប ដែលហៅថា ភ្នាក់ងារគណបក្សនយោបាយ ដើម្បីសង្កេតមើលដំណើរការចុះឈ្មោះបោះឆ្នោត។ ជាទូទៅការអនុវត្តជាក់ស្តែង គណបក្សអាចដាក់ជាបញ្ជីមកក្រុមប្រឹក្សាឃុំ សង្កាត់ សម្រាប់ឃុំ សង្កាត់នីមួយៗ ប៉ុន្តែ គ.ជ.ប ផ្តល់សន្លឹកបណ្ណតែ ២ ប៉ុណ្ណោះ សម្រាប់ពេញសិទ្ធិ ១ និងបម្រុង ១។ ក្នុងករណីមានការផ្លាស់ប្តូរភ្នាក់ងារបន្ថែមលើភ្នាក់ងារទាំង ២ នោះ

ត្រូវរាយការណ៍ជូនក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីស្នើសុំបណ្តេបន្ថែមទៀត។ នេះជាយន្តការរបស់ គ.ជ.ប បានអនុវត្តកន្លងមកយើងក៏ពុំមានបញ្ហាអ្វីដែលគួរឱ្យកត់សម្គាល់ទេ។

- អំពីអ្នកសង្កេតការណ៍ជាតិចល័ត។ ជាគោលការណ៍និយមន័យនៃអ្នកសង្កេតការណ៍ចល័ត គ.ជ.ប បានកំណត់ក្នុងក្រមសីលធម៌រួចហើយ ចំណុចនេះ គ.ជ.ប សូមបញ្ជាក់ជូនថា កន្លងមកទាក់ទងនឹងការស្នើសុំនេះពុំដែលមានបញ្ហាអ្វីនោះទេ គ.ជ.ប ធ្វើការបដិសេធបាន លុះត្រាតែអ្នកទាំងនោះមិនគ្រប់អាយុ ឬឈ្មោះស្ងួនប៉ុណ្ណោះ។ ដូចនេះ សូមអង្គការសមាគម កុំមានការព្រួយបារម្ភណ៍អំពីបញ្ហានេះ ប៉ុន្តែសាមីអង្គការសមាគម ត្រូវទទួលខុសត្រូវចំពោះបញ្ជីអ្នកសង្កេតការណ៍របស់ខ្លួន។ ចំពោះយោបល់លើកឡើងរបស់តំណាងអង្គការខុមហ្វ្រែល និងតំណាងអង្គការតម្លាភាពកម្ពុជា ទាក់ទងនឹងលក្ខណសម្បត្តិរបស់អ្នកសង្កេតការណ៍ចល័ត គ.ជ.ប សូមទទួលយក។

ជំពូកទី៦ ដំណើរការធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោត និងការចុះឈ្មោះបោះឆ្នោត

នៅក្នុងជំពូកនេះ ភាគីពាក់ព័ន្ធបានផ្តល់យោបល់ច្រើនទាក់ទងនឹងនីតិវិធីអនុវត្តក្នុងការធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោត និងចុះឈ្មោះបោះឆ្នោត ហើយមតិយោបល់មួយចំនួន គ.ជ.ប បានទទួលយកដាក់បញ្ចូលក្នុងបទបញ្ជា និងនីតិវិធីនេះ។ គ.ជ.ប សូមធ្វើការបញ្ជាក់ជូនអង្គពិធីជារួម ទាំងមតិយោបល់ដែលបានបញ្ជូនមក និងការលើកឡើងកាលពីព្រឹកម៉ិញ តាមចំណុចដូចខាងក្រោម៖

- ការលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត។ ចំពោះចំណុចនេះ គ.ជ.ប ធ្វើការងារដោយប្រុងប្រយ័ត្នបំផុត ពិសេសទាក់ទងនឹងឯកសារសំអាង។ យើងនឹងកំណត់ជាគោលការណ៍អំពីឯកសារសំអាងថា តើត្រូវយកកម្រិតណា។ ជាទូទៅយើងផ្អែកលើឯកសារផ្លូវការរបស់អាជ្ញាធរមានសមត្ថកិច្ចតាមមូលដ្ឋាន ជាឧទាហរណ៍ មរណភាពត្រូវមានលិខិតមរណភាព ការផ្លាស់ទីលំនៅចេញត្រូវមានឯកសារបញ្ជាក់ច្បាស់

លាស់អំពីការផ្ទេរចេញរបស់ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ ការដក សិទ្ធិបោះឆ្នោតជាបណ្តោះអាសន្នដោយសេចក្តីសម្រេចរបស់ គ.ជ.ប និងសាលក្រមរបស់តុលាការ។ ដូចនេះ យើងនឹងពង្រឹងការអនុវត្តក្នុងកិច្ចការនេះ ហើយករណីលុបក៏ត្រូវស្នើមក គ.ជ.ប ផងដែរ។ គ.ជ.ប នឹងពិនិត្យដោយយកចិត្តទុកដាក់បំផុត។ ទាក់ទងនឹងការលុបនេះដែរ មានអនុសាសន៍មួយចំនួនបានលើកឡើងថា ឱ្យមានការអង្កេតហេតុផលនៃការលុប និងចាត់វិធានការការលុបឈ្មោះមិនត្រឹមត្រូវ។ ករណីនេះ យើងនឹងអង្កេតតាមរយៈយន្តការពិនិត្យ ផ្ទៀងផ្ទាត់ឯកសារផ្លូវការរបស់អាជ្ញាធរពាក់ព័ន្ធ នឹងឈ្មោះ ទិន្នន័យក្នុងបញ្ជីបោះឆ្នោតបន្ថែមទៀត ដើម្បីឱ្យកាន់តែច្បាស់ ហើយប្រសិនបើមានការលុបឈ្មោះដោយមិនត្រឹមត្រូវ គ.ជ.ប នឹងចាត់វិធានការភ្លាម។

- អំពីការស្នើសុំឱ្យរក្សាទុកឈ្មោះ អ្នកដែលត្រូវបានដកហូតជាបណ្តោះអាសន្ននូវសិទ្ធិបោះឆ្នោតក្នុងប្រព័ន្ធកុំព្យូទ័រ។ ចំណុចនេះ ច្បាប់បោះឆ្នោតបានតម្រូវឱ្យស្មៀនឃុំ សង្កាត់ស្រង់ចូលបញ្ជីលុប ដោយផ្អែកលើឯកសារសំអាងច្បាស់លាស់។ ដូចនេះ ជាការអនុវត្ត គ.ជ.ប ត្រូវតែលុបចេញពីបញ្ជីបោះឆ្នោត ហើយប្រសិនបើសាមីជននោះត្រូវបានផ្តល់សិទ្ធិឡើងវិញ សាមីជននោះ ត្រូវតែបង្ហាញខ្លួន និងបំពេញលក្ខខណ្ឌចុះឈ្មោះបោះឆ្នោតឡើងវិញ ស្របតាមការកំណត់នៃច្បាប់។
- អំពីលក្ខខណ្ឌចុះឈ្មោះបោះឆ្នោត និងលក្ខខណ្ឌមានឈ្មោះក្នុងបញ្ជីបោះឆ្នោត។
  - លក្ខខណ្ឌដើម្បីចុះឈ្មោះបោះឆ្នោត មានចែងច្បាស់ក្នុងមាត្រា ៥១ នៃច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងបទបញ្ជា និងនីតិវិធីដែលយើងកំពុងពិភាក្សានេះ។ មានន័យថា ទីមួយ សាមីខ្លួនត្រូវបង្ហាញខ្លួននៅចំពោះមុខក្រុមចុះឈ្មោះបោះឆ្នោតនិងមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬឯកសារបញ្ជាក់អត្តសញ្ញាណ ទីពីរមានសញ្ជាតិ

ខ្មែរ ទីបី មានអាយុ ១៨ ឆ្នាំឡើងទៅ គិតដល់ថ្ងៃបោះឆ្នោត ទីបួនមានលំនៅឋាន ឬទីសំណាក់ក្នុងឃុំ សង្កាត់ដែលសាមីខ្លួនត្រូវបោះឆ្នោត។ ចំណុចនេះ គ.ជ.ប សូមបញ្ជាក់ជូនឱ្យបានច្បាស់ថា ចុះឈ្មោះនៅឃុំ សង្កាត់ណា ត្រូវបោះឆ្នោតនៅឃុំ សង្កាត់នោះ និងទីប្រាំ មិនទាន់បានចុះឈ្មោះ ឬបានចុះឈ្មោះបោះឆ្នោតនៅឃុំ សង្កាត់ផ្សេងណាមួយរួចហើយ។ ទាំងអស់នេះគឺជាលក្ខខណ្ឌដើម្បីចុះឈ្មោះបោះឆ្នោតដែល គ.ជ.ប បានអនុវត្តកន្លងមក។ ភ្ជាប់ជាមួយការលើកឡើងកាលពីព្រឹកថា តើឯកសារអ្វីខ្លះដែលត្រូវប្រើប្រាស់សម្រាប់ការចុះឈ្មោះបោះឆ្នោត គ.ជ.ប សូមបញ្ជាក់ជូនថា ឯកសារគោលចម្បងសម្រាប់ចុះឈ្មោះបោះឆ្នោត និងបោះឆ្នោត គឺអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ។ ក្នុងករណីគ្មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬបាត់ ឬខូច គាត់ត្រូវបំពេញបែបបទស្នើសុំឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោតជាមួយអាជ្ញាធរឃុំ សង្កាត់ ដោយត្រូវនាំទៅជាមួយនូវសាក្សី ២ រូប ដែលមានសិទ្ធិបោះឆ្នោតនៅក្នុងឃុំ សង្កាត់នោះ សំបុត្រកំណើតច្បាប់ដើម ឬសេចក្តីចម្លងសំបុត្រកំណើតច្បាប់ និងឯកសារផ្លូវការផ្សេងៗទៀតដែលបញ្ជាក់អំពីសញ្ជាតិ និងរូបថតទំហំ ៣ គុណ ៤ ចំនួន ២ សន្លឹក។ ចំពោះអ្នកដែលមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរហើយ ប៉ុន្តែអាសយដ្ឋានក្នុងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរផ្សេងពីលំនៅឋាន ឬទីសំណាក់ដែលសាមីខ្លួនត្រូវចុះឈ្មោះបោះឆ្នោត សាមីជននោះអាចបង្ហាញសៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅច្បាប់ដើម អមជាមួយអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ដើម្បីចុះឈ្មោះបោះឆ្នោត។ ប៉ុន្តែប្រសិនបើ គ្មានសៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ ត្រូវទៅជួបអាជ្ញាធរឃុំ សង្កាត់ ដើម្បីស្នើសុំលិខិតបញ្ជាក់ទីលំនៅ។

- អំពីលក្ខខណ្ឌមានឈ្មោះក្នុងបញ្ជីបោះឆ្នោត មានចែងច្បាស់នៅក្នុងមាត្រា ៤៦ នៃច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ មានន័យថា អ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោតដែលមិនអាចបំពេញបានត្រឹមត្រូវតាមលក្ខខណ្ឌដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតតាមមាត្រា ៤៦ អាចនឹងត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត តាមរយៈការប្តឹងជំទាស់ នៅពេលបិទផ្សាយបញ្ជីបោះឆ្នោតដំបូង។ ដូចនេះ រាល់បណ្តឹងជំទាស់ដែលទាក់ទងនឹងការលុបឈ្មោះ ត្រូវតែមានឯកសារភស្តុតាងច្បាស់លាស់។ ដូចការលើកឡើងរបស់តំណាងអង្គការខុមហ្រ្វែល ទាក់ទងនឹងស្ថានភាពជាប់ពន្ធនាគារ គឺស្មារតីច្បាស់ និងនិយាមអន្តរជាតិកំណត់ថា ជាទណ្ឌិត ដែលសំដៅទៅដល់ការចូលជាស្ថាពរនៃសាលក្រម ឬសាលដីការបស់តុលាការ។ ចំណុចនេះ គ.ជ.ប នឹងធ្វើការពិចារណាឱ្យបានល្អិតល្អន់ក្នុងក្របខណ្ឌច្បាប់ពាក់ព័ន្ធជាធរមាននៅកម្ពុជា។

ដូចនេះ ឯកសារសម្រាប់បម្រើការចុះឈ្មោះបោះឆ្នោត គឺអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោត ទន្ទឹមមានឯកសារផ្លូវការមួយចំនួនទៀត ដើម្បីបំពេញបន្ថែមលើលក្ខខណ្ឌសម្រាប់ការចុះឈ្មោះបោះឆ្នោត។ ឆ្លៀតក្នុងឱកាសនេះ គ.ជ.ប សូមជម្រាបជូន និងអំពាវនាវដល់ប្រជាពលរដ្ឋ និងភាគីពាក់ព័ន្ធទាំងអស់សូមត្រៀមលក្ខណសម្បត្តិ ដើម្បីចូលរួមអនុវត្តតាមតួនាទី ដើម្បីធ្វើឱ្យដំណើរការធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោត និងការចុះឈ្មោះបោះឆ្នោត ប្រព្រឹត្តទៅដោយជោគជ័យ។

- អំពីការចុះឈ្មោះបោះឆ្នោត មានការលើកឡើងថា គួរចុះឈ្មោះបោះឆ្នោតចល័ត ដល់តាមទីជនបទ តាមភូមិ និងវត្តអារាម ជាទូទៅដំណើរការចុះឈ្មោះបោះឆ្នោតចាប់ផ្តើមដំបូងនៅសាលាឃុំ សង្កាត់ ហើយបន្ទាប់មក ក្រុមប្រឹក្សាឃុំ សង្កាត់ និងក្រុមចុះឈ្មោះបោះឆ្នោត នឹង

កំណត់ប្រតិទិនសម្រាប់ការចុះឈ្មោះបោះឆ្នោតចល័តទៅតាមភូមិមួយចំនួន ដើម្បីបង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋដែលមានការលំបាកក្នុងការមកស្នើសុំចុះឈ្មោះបោះឆ្នោត ឬភូមិដែលមានស្ថានភាពភូមិសាស្ត្រសុគស្មាញ ហើយនឹងមកបញ្ចប់នៅតាមសាលាឃុំ សង្កាត់វិញ ដូចនេះ ការលើកឡើង គឺស្របនឹងការអនុវត្តរបស់ គ.ជ.ប។ ចំពោះព្រះសង្ឃ គ.ជ.ប បន្តពង្រឹងការផ្សព្វផ្សាយឱ្យបានទូលំទូលាយបន្ថែមទៀតនៅតាមវត្ត អារាម។

- អំពីការដាក់ស្ថានភាពពិការក្នុងបញ្ជីបោះឆ្នោត។ គ.ជ.ប បានដាក់បញ្ចូលហើយក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យបញ្ជីបោះឆ្នោត អំពីស្ថានភាពពិការ ៣ ប្រភេទ ដែលមាន ពិការភ្នែកទាំងសងខាង ពិការដៃទាំងសងខាង និងពិការជើងទាំងសងខាង។ ដូចនេះ ការងារនេះ យើងបានផ្តល់កិច្ចសហការលើកកម្ពស់ និងបង្កលក្ខណៈដល់ជនមានពិការភាព ឱ្យចូលរួមក្នុងដំណើរការបោះឆ្នោត ប៉ុន្តែទាក់ទងនឹងការបង្ហាញស្ថានភាពពិការនៅលើបញ្ជីបោះឆ្នោតផ្លូវការនោះ គ.ជ.ប ត្រូវការពិនិត្យសិក្សាស្វែងយល់បន្ថែមអំពីសិទ្ធិ និងបំណងរបស់បុគ្គលនីមួយៗដែលមានពិការភាព។
- អំពីលិខិតបញ្ជាក់ទីលំនៅ។ ចំណុចនេះ មានការលើកឡើងច្រើនអំពីរយៈពេលកំណត់ច្បាស់លាស់មួយ ការពង្រឹងនីតិវិធីនៃការចេញលិខិតបញ្ជាក់ទីលំនៅ ការបំពេញបន្ថែមខ្លឹមសារប្រកាសរបស់ក្រសួងមហាផ្ទៃទៅក្នុងបទបញ្ជា និងនីតិវិធី ក្នុងនោះក៏មានការលើកឡើងស្នើឱ្យនិយោជកតាមសហគ្រាស ឬក្រុមហ៊ុនផ្សេងៗ អាចផ្តល់ការបញ្ជាក់អំពីការស្នាក់នៅរបស់កម្មករ និយោជិតផងដែរ។ ទាក់ទងនឹងបញ្ហានេះ ច្បាប់បោះឆ្នោតបានបញ្ញត្តឱ្យអាជ្ញាធរឃុំ សង្កាត់មានសមត្ថកិច្ចចេញលិខិតបញ្ជាក់ទីលំនៅនេះ ហើយជាក់ស្តែងយើងអនុវត្តតាមប្រកាសរបស់ក្រសួងបហាផ្ទៃ។ រាល់រនុសាសន៍ដែលបានលើកឡើង

នេះ គ.ជ.ប នឹងទទួលយកពិចារណាក្នុងក្របខណ្ឌច្បាប់ ដោយអាច នឹងស្នើសុំកិច្ចសហការបន្ថែមជាមួយក្រសួងមហាផ្ទៃ លើកលែងតែ ការលើកឡើងដែលស្នើឱ្យនិយោជកអាចចេញលិខិតបញ្ជាក់ទីលំនៅ នោះ គ.ជ.ប មិនអាចទទួលយកបានឡើយ។

- អំពីការស្នើសុំបញ្ជីបោះឆ្នោតដំបូង និង Soft បញ្ជីបោះឆ្នោត។ ចំពោះករណីនេះ គ.ជ.ប សូមបញ្ជាក់ថា បញ្ជីបោះឆ្នោតដំបូង គឺយើងអាចផ្តល់ជូនភាគីពាក់ព័ន្ធ ដូចជាគណបក្សនយោបាយជាដើម តាមតម្លៃផលិត ហើយចំពោះទិន្នន័យទន់ (Soft Copy) នោះ គ.ជ.ប មិនអាចផ្តល់ជូនបានទេ ប៉ុន្តែ គ.ជ.ប បានផ្តល់កិច្ចសហការជាមួយភាគីពាក់ព័ន្ធនោះ គឺយើងអាចអនុញ្ញាតឱ្យភាគីពាក់ព័ន្ធអញ្ជើញមកពិនិត្យ ផ្ទៀងផ្ទាត់នៅនាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោតបាន ដោយមានការសម្របសម្រួលពីអ្នកបច្ចេកទេសរបស់ គ.ជ.ប។
- ចំពោះការស្នើសុំបើកឱ្យមានការកែតម្រូវទិន្នន័យក្នុងពេលចុះឈ្មោះ។ ជាលក្ខណៈបច្ចេកទេសអ្នកដែលស្នើសុំចុះឈ្មោះបោះឆ្នោតថ្មី នៅពេលដែលទិន្នន័យរបស់ខ្លួនត្រូវបានក្រុមចុះឈ្មោះបោះឆ្នោតបញ្ជូនមក គ.ជ.ប ហើយ មិនអាចកែតម្រូវបានឡើយ។ ប៉ុន្តែទន្ទឹមនេះ គ.ជ.ប ក៏មានយន្តការការពារកំហុសឆ្គងរបស់ការីផ្ទៀងផ្ទាត់ផងដែរ តាមរយៈការដាក់ Monitor ទី២ ដែលអាចឱ្យអ្នកសុំចុះឈ្មោះបោះឆ្នោតជួយពិនិត្យផ្ទៀងផ្ទាត់នៅពេលការីកុំព្យូទ័របញ្ចូលទិន្នន័យ នេះគឺជាការយកចិត្តទុកដាក់របស់យើង។
- ការផ្ទៀងផ្ទាត់តួលេខអ្នកចុះឈ្មោះបោះឆ្នោតប្រចាំថ្ងៃ។ ក្នុងការអនុវត្តលទ្ធផលចុះឈ្មោះបោះឆ្នោតប្រចាំថ្ងៃនេះ ក្រុមចុះឈ្មោះបោះឆ្នោតត្រូវធ្វើការផ្ទៀងផ្ទាត់ជាមួយលទ្ធផលចុះឈ្មោះបោះឆ្នោតដែលមានក្នុងប្រព័ន្ធកុំព្យូទ័រ និងផ្ទៀងផ្ទាត់បន្ថែមជាមួយបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត។ ដូចនេះ គ.ជ.ប នឹងពង្រឹងការអនុវត្តការងារនេះបន្ថែមទៀតដើម្បីឱ្យកាន់តែមានប្រសិទ្ធភាព។

- អំពីយន្តការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ទិន្នន័យអ្នកចុះឈ្មោះបោះឆ្នោតនៅ គ.ជ.ប មានការលើកឡើងស្នើឱ្យធ្វើការបញ្ចូលទិន្នន័យមួយចំនួននៅ គ.ជ.ប ដើម្បីជួយកាត់បន្ថយកំហុសរបស់ក្រុមចុះឈ្មោះបោះឆ្នោត។ ទាក់ទងនឹងបញ្ហានេះ តាមការសង្កេតជាទូទៅ ភាគរយនៃកំហុសឆ្គងរបស់ក្រុមចុះឈ្មោះបោះឆ្នោត ក្នុងការបញ្ចូលទិន្នន័យមានកម្រិតតិចតួច ប៉ុន្តែទោះជាយ៉ាងនេះក្តី គ.ជ.ប នឹងពង្រឹងការអនុវត្តតាមរយៈការពង្រឹងការបណ្តុះបណ្តាល និងការជួបប្រជុំពិភាក្សា ១០ថ្ងៃម្តង ដើម្បីពិនិត្យមើលដំណើរការងាររបស់ក្រុមចុះឈ្មោះបោះឆ្នោត។ ទាក់ទងនឹងការងារបច្ចេកទេសនេះ គ.ជ.ប នឹងបន្តសហការ ពិភាក្សាកែលម្អជាមួយនឹងអ្នកជំនាញការបន្ថែមទៀត ដើម្បីធ្វើយ៉ាងណាឱ្យកាន់តែប្រសើរឡើង។

ជំពូកទី៧ ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹង

នៅក្នុងជំពូកនេះ មានយោបល់មួយចំនួនបានលើកឡើងទាក់ទងនឹងយន្តការអង្កេតស្រាវជ្រាវលើបណ្តឹង ការបង្កើតគណៈកម្មការអង្កេតលើបណ្តឹង និងនីតិវិធីនៃការប្រគល់-ទទួលសម្រង់សេចក្តីសម្រេច (ទម្រង់បែបបទលេខ ១២០៣) ជាដើម។ ទាក់ទងនឹងបញ្ហានេះ គ.ជ.ប សូមបញ្ជាក់ថា បណ្តឹងដែលកើតឡើងក្នុងដំណើរការចុះឈ្មោះបោះឆ្នោតមាន ២ ប្រភេទ គឺទីមួយ បណ្តឹងដែលនាំឱ្យមានការកែតម្រូវ និងបណ្តឹងដែលសុំឱ្យមានការដាកពិន័យតាមច្បាប់បោះឆ្នោត។ បណ្តឹងទាំង ២ ប្រភេទនេះ យើងដោះស្រាយតាមយន្តការផ្សេងៗគ្នា៖

- ទីមួយ បណ្តឹងដែលនាំឱ្យមានការកែតម្រូវ គឺយើងអនុវត្តគោលការណ៍ និងកាលបរិច្ឆេទដែលកំណត់ដោយច្បាប់បោះឆ្នោត និងទីពីរ បណ្តឹងដែលនាំឱ្យមានការដាកពិន័យតាមច្បាប់បោះឆ្នោត យើងអនុវត្តការប្តឹងមានរយៈពេល ៣ ថ្ងៃយ៉ាងយូរបន្ទាប់ពីថ្ងៃកើតហេតុ និងដោះស្រាយក្នុងរយៈពេលសមស្របជាបន្ទាន់។ ទាក់ទងនឹងយន្តការអង្កេតស្រាវជ្រាវនេះ គ.ជ.ប បានអនុវត្តយ៉ាងត្រឹមត្រូវ ច្បាស់លាស់ ដោយផ្អែកលើអង្គហេតុ និងអង្គច្បាប់។ ក្នុងករណីចាំបាច់ សមាជិក គ.ជ.ប អាចដឹកនាំចុះធ្វើការស៊ើបអង្កេតស្រាវជ្រាវលើបណ្តឹងតែម្តង។ នេះជាយន្តការដែល គ.ជ.ប

បានអនុវត្តកន្លងមក ដើម្បីបង្កើនតម្លាភាព និងភាពអាចទទួលយកបាន។ ប៉ុន្តែទោះជាយ៉ាងណា ទាក់ទងនឹងការងារការដាក់ ការទទួល និងការដោះស្រាយបណ្តឹង នាយកដ្ឋានជំនាញនៃ គ.ជ.ប បានពិភាក្សាយ៉ាងជិតស្និតជាមួយអ្នកជំនាញការប្រចាំ គ.ជ.ប ដើម្បីធ្វើការកែលម្អនីតិវិធីមួយឱ្យកាន់តែល្អប្រសើរ។

- ចំពោះនីតិវិធីប្រគល់ ទទួលសម្រង់សេចក្តីសម្រេច (ទម្រង់បែបបទលេខ ១២០៣) បច្ចុប្បន្ននាយកដ្ឋានជំនាញរបស់ គ.ជ.ប កំពុងសិក្សារៀបចំនីតិវិធីនេះ ឱ្យកាន់តែច្បាស់លាស់ថែមទៀត ហើយនឹងដាក់ជូន គ.ជ.ប ដើម្បីពិនិត្យ សម្រេច។

រាល់បណ្តាអនុសាសន៍ដ៏ល្អៗរបស់ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលបានលើកឡើងក្នុងកិច្ចប្រជុំពិភាក្សារយៈពេលពេញមួយថ្ងៃនេះ បានធ្វើឱ្យ គ.ជ.ប មានមូលដ្ឋានក្នុងការកែលម្អលើបទបញ្ជា និងនីតិវិធី ដែលនឹងត្រូវសម្រេចជាផ្លូវការ នាពេលខាងមុខ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមផ្តាំផ្ញើដល់លោក លោកស្រីដែលជាប្រធាន និងអនុប្រធានលេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត ដែលបានចូលរួមក្នុងកិច្ចប្រជុំនេះ ត្រូវបន្តសិក្សាស្វែងយល់បន្ថែមទៀតនៅពេលដែលបទបញ្ជា និងនីតិវិធីនេះ ត្រូវបាន គ.ជ.ប សម្រេចអនុម័តដាក់ឱ្យប្រើប្រាស់ជាផ្លូវការ ដើម្បីជាមូលដ្ឋានសម្រាប់ធ្វើការបណ្តុះបណ្តាលដល់ក្រុមចុះឈ្មោះបោះឆ្នោត ព្រមទាំងភាគីពាក់ព័ន្ធនៅតាមរាជធានី ខេត្ត នៅពេលប្រតិបត្តិការធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោត និងការចុះឈ្មោះបោះឆ្នោតខាងមុខ។

ឯកឧត្តម លោកជំទាវ លោក លោកស្រីជាទីគោរព!

រាល់អនុសាសន៍ និងមតិយោបល់ដែលបានលើកឡើងរបស់ភាគីពាក់ព័ន្ធនាឱកាសនេះ គ.ជ.ប នឹងបន្តពិភាក្សាពិនិត្យលទ្ធភាពបន្ថែមទៀត ដើម្បីដាក់បញ្ចូលក្នុងបទបញ្ជា និងនីតិវិធី សំដៅធ្វើយ៉ាងណាឱ្យបទបញ្ជា និងនីតិវិធីសម្រាប់ការធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោត និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១៧ ឱ្យកាន់តែប្រសើរឡើង។

ក្នុងនាម គ.ជ.ប និងក្នុងនាម **ឯកឧត្តម ស៊ុក ប៊ុនហុក** ប្រធាន គ.ជ.ប ខ្ញុំ សូមសម្តែងនូវអំណរគុណយ៉ាងជ្រាលជ្រៅបំផុត រួមទាំងការកោតសរសើរ និង វាយតម្លៃខ្ពស់ចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់ ដែលបាន ចំណាយពេលវេលាដ៏មានតម្លៃ និងប្រាជ្ញាស្មារតីក្នុងការផ្តល់ជាមតិយោបល់ យ៉ាងផុលផុស ញ៉ាំងឱ្យកិច្ចប្រជុំពិគ្រោះយោបល់នេះ ទទួលបានលទ្ធផលគួរជាទី មោទន:។ ផ្តើមចេញពីបទបញ្ជា និងនីតិវិធីមួយដែលមានការរៀបចំបានត្រឹមត្រូវ ល្អតាមច្បាប់នេះហើយ អាចធ្វើឱ្យ គ.ជ.ប រៀបចំការបោះឆ្នោតនាពេលខាងមុខ ទទួលបានជោគជ័យ ដែលនឹងធានាបាននូវភាពសុខដុមរមនាសម្រាប់ប្រជាជាតិ ខ្មែរទាំងមូលក្រោយការបោះឆ្នោត។

មុននឹងបញ្ចប់នេះ ជូសមុខឱ្យ គ.ជ.ប ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះអង្គការ JICA ដែលបានផ្តល់ជំនួយជាថវិកាសម្រាប់រៀបចំកិច្ចប្រជុំពិគ្រោះ យោបល់នេះឡើង និងសូមថ្លែងអំណរគុណដល់សហភាពអ៊ឺរ៉ុបដែលបានចូលរួម ពិនិត្យ និងផ្តល់យោបល់លើបទបញ្ជា និងនីតិវិធីនេះ។

ជាទីបញ្ចប់ ខ្ញុំសូមប្រសិទ្ធពរបវរសួស្តី ជ័យមង្គលជូនដល់ឯកឧត្តម លោក ជំទាវ លោក លោកស្រី គណៈអធិបតី ភ្ញៀវជាតិ និងអន្តរជាតិ ឱ្យជួបតែពុទ្ធពរ ទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ខ្ញុំសូមប្រកាសបិទកិច្ចពិគ្រោះយោបល់ ចាប់ពីពេលនេះតទៅ។

សូមអរគុណ!